DSHS
WASHINGTON STATE
Department of Social and Health Services

សេវាកម្មសហគមន៍ពិការភាពផ្នែកលូតលាស់
(Developmental Disabilities Community Services, DDCS)

សេចក្តីជូនដំណឹងអំពីកិច្ចប្រជុំរៀបចំផែនការសេវាកម្មដែលផ្តោតលើបុគ្គល និងវាយតម្លៃប្រចាំឆ្នាំ

Person-Centered Service Planning and Annual Assessment Meeting Notice

កាលបរិច្ឆេទ៖

ឈ្មោះ និងអាសយដ្ឋាន

ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាង

ជូនចំពោះ៖

កិច្ចប្រជុំវាយតម្លៃប្រចាំឆ្នាំ និងរៀបចំផែនការសេវាកម្មផ្តោតលើបុគ្គលរបស់អ្នកត្រូវធ្វើឡើងក្នុងរយៈពេល 60 ថ្ងៃគិតចាប់ពីថ្ងៃផ្ញើលិខិតនេះ។ ខ្ញុំនឹងទូរសព្ទទៅអ្នកដើម្បីកំណត់ពេលកិច្ចប្រជុំ ឬអ្នកអាចទូរសព្ទមកខ្ញុំផ្ទាល់ក៏បាន។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ សូមប្រាប់ខ្ញុំឱ្យបានដឹង។

នេះគឺជា**កិច្ចប្រជុំរៀបចំផែនការ**របស់អ្នក ដូច្នេះ**អ្នក**ត្រូវតែធ្វើការសម្រេចចិត្តថាតើត្រូវរៀបចំវាបែបណា។ អ្នកអាចជ្រើសរើសពេលវេលាដែលត្រូវប្រារព្ធឡើង ទីកន្លែងដែលត្រូវប្រារព្ធឡើង អ្នកណាខ្លះដែលអ្នកចង់ឱ្យចូលរួម និងជ្រើសរើសថា តើត្រូវប្រជុំផ្ទាល់ ឬតាមរយៈប្រព័ន្ធវីដេអូ។
ប្រសិនបើការវាយតម្លៃនេះមិនបានធ្វើឡើងនៅផ្ទះរបស់អ្នកទេ ខ្ញុំនឹងនៅតែមកជួបអ្នកដល់ផ្ទះក្នុងពេលបន្តិចទៀតនេះ មុនពេល ឬក្រោយពេលការវាយតម្លៃរបស់អ្នក។

ក្នុងអំឡុងពេលកិច្ចប្រជុំរបស់អ្នក យើងនឹងអនុវត្តតាមការណែនាំ**របស់អ្នក**ដើម្បីបង្កើតផែនការរបស់អ្នក៖

- សូមអញ្ជើញនរណាម្នាក់ដែលអ្នកចង់ឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់អ្នក រួមទាំងមនុស្សដែលស្គាល់អ្នកច្បាស់បំផុតផងដែរ។
- ខ្ញុំចង់ស្តាប់អំពីគោលដៅ និងបំណងប្រាថ្នារបស់អ្នក រួមទាំងសេវាកម្ម និងការគាំទ្រនានាដែលអ្នកចង់បាន ហើយខ្ញុំនឹងដាក់បញ្ចូលវាទៅក្នុងផែនការរបស់អ្នក។
- ខ្ញុំអាចនឹងត្រូវទូរសព្ទទៅអ្នកផ្តល់សេវាកម្មរបស់អ្នក ឬអ្នកផ្សេងទៀត ដើម្បីសាកសួរព័ត៌មានអំពីការគាំទ្រដែលពួកគេកំពុងផ្តល់ជូន។

សូមទាក់ទងមកខ្ញុំ ប្រសិនបើអ្នកមានសំណួរ ឬក្តីកង្វល់ណាមួយ។

ខ្ញុំទន្ទឹងរង់ចាំជួបជាមួយអ្នក។

សូមអរគុណ

_____
ឈ្មោះអ្នកគ្រប់គ្រងករណី

_____
ទូរសព្ទ

_____
អាសយដ្ឋានអ៊ីមែល

ខាងក្រោមនេះគឺជាធនធានមួយចំនួនដែលនឹងជួយអ្នកក្នុងការត្រៀមខ្លួនសម្រាប់កិច្ចប្រជុំរបស់អ្នក៖

- ឧបករណ៍រៀបចំផែនការដែលផ្តោតលើបុគ្គល៖ www.mylifeplan.guide
- ព័ត៌មានស្តីពីការគាំទ្រក្នុងការធ្វើសេចក្តីសម្រេចចិត្ត៖ https://informingfamilies.org/topic/sdm/
- ធនធានវាយតម្លៃការគាំទ្រ៖ https://www.dshs.wa.gov/dda/consumers-and-families/dda-assessment

របៀបរាយការណ៍អំពីការរំលោភបំពាន និងការមិនយកចិត្តទុកដាក់៖

- ចំពោះមនុស្សពេញវ័យដែលងាយរងគ្រោះ៖ https://www.dshs.wa.gov/altsa/home-and-community-services/report-concerns-involving-vulnerable-adults
- ចំពោះកុមារ៖ https://www.dcyf.wa.gov/safety/report-abuse ឬ
- សូមហៅទៅលេខ 1-866-ENDHARM (1-866-363-4276)
    - 1-866-EndHarm ដែលអាចចូលប្រើប្រព័ន្ធ TTY។ បុគ្គលិកម្នាក់នឹងទទួលការហៅទូរសព្ទរបស់អ្នក 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។
    - បុគ្គលដែលមានពិការភាពក្នុងការនិយាយ ឬការស្តាប់ អាចប្រើប្រាស់មធ្យោបាយដូចខាងក្រោមដើម្បីទាក់ទងមកយើងខ្ញុំ៖
        - ធ្វើការហៅទូរសព្ទដោយផ្ទាល់តាមរយៈ TTY ទៅកាន់ខ្សែទូរសព្ទ TTY ពិសេស៖ **1-800-624-6186**។
        - បុគ្គលដែលមានបញ្ហាក្នុងការស្តាប់ ហើយមានឧបករណ៍ទូរគមនាគមន៍ពិសេសអាចហៅទៅកាន់លេខ 866-363-4276 (End Harm) តាមរយៈ សេវាកម្មបញ្ជូនបន្តរបស់រដ្ឋ Washington។

ឯកសារភ្ជាប់មកជាមួយ៖ ខិតប័ណ្ណកម្មវិធីលើកលែង HCBS (Home and community-Based Services,សេវាបម្រើតាមផ្ទះនិងសហគមន៍) (DSHS 22-605)
ខិតប័ណ្ណផែនទីបង្ហាញផ្លូវទៅកាន់សេវាកម្មនានា (DSHS 22-822)
ប្រូហ្វាលទំព័ររបស់ខ្ញុំ (DSHS 22-1753)
តារាងសេវាកម្ម (DSHS 22-203)
ខិតប័ណ្ណអំពីរបៀបរាយការណ៍អំពីការរំលោភបំពាន និងការមិនយកចិត្តទុកដាក់

ចម្លងជូន៖ អ្នកតំណាង NSA (Necessary Supplemental Accommodation, អ្នកតំណាងទីភ្នាក់ងារសន្តិសុខជាតិ)

ការណែនាំសម្រាប់សេចក្តីជូនដំណឹងអំពីកិច្ចប្រជុំរៀបចំផែនការសេវាកម្មផ្តោតលើបុគ្គល និងវាយតម្លៃប្រចាំឆ្នាំ

តើខ្ញុំត្រូវប្រើទម្រង់បែបបទនេះនៅពេលណា?

អ្នកប្រើទម្រង់បែបបទនេះ ដើម្បីជូនដំណឹងដល់អតិថិជន និងអាណាព្យាបាលស្របច្បាប់
ឬអ្នកតំណាងរបស់អតិថិជនអំពីការវាយតម្លៃដែលនឹងមកដល់ និងកិច្ចប្រជុំរៀបចំផែនការសេវាកម្មផ្តោតលើបុគ្គល
យ៉ាងហោចណាស់ 60 ថ្ងៃ មុនពេលបញ្ចប់រយៈពេលនៃផែនការ។